# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណីលេខ៖៣២៤

ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩

សាលក្រមលេខ: ៥៣(ង)/៥៦៩

ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩

## សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូង ខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទីម្ភៃពីរ ខែកក្កដា ឆ្នាំពីរពាន់ដប់ប្រាំបួន វេលាម៉ោងបី និងសាមសិបនាទីរសៀលដោយមានសមាសភាពចូលរួមដូចតទៅ៖

## ចៅក្រមជំនុំជម្រះ

លោក **ម៉ុក សុវណ្ណមុន្នី** ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

## ក្រឡាបញ្ជីសវនាការ

លោក **ផៃ ឈុនណា** ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

-ដើមចោទឈ្មោះ **ដ** ភេទស្រី អាយុ ៥៧ ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាននៅ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយឈ្មោះ **ច១** ភេទប្រុស អាយុ ៤៣ ឆ្នាំ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ **ច២** សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ ខេត្តបន្ទាយមានជ័យ។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

I. ការទាមទាររបស់ដើមចោទ

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ **ច១** និងប្រពន្ធឈ្មោះ **ច២** សងប្រាក់ជំពាក់ប្រាក់ដើមសរុបចំនួន ៥០០០ (ប្រាំពាន់) ដុល្លាអាមេរិក ។

២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ **ច១** និងប្រពន្ធឈ្មោះ **ច២** សងសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាជាប្រាក់ក្នុងម្នាក់ៗចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

៣. សុំអនុវត្តបណ្តោះអាសន្នលើចំណុចទី១ និងចំណុចទី២ ។

៤. ឱ្យចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗ។

II. ការអះអាងរបស់គូភាគី

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

១. សេចក្តីថ្លែងការណ៍របស់ដើមចោទៈ

ដើមចោទបានអះអាងថា៖ កាលពីឆ្នាំ២០១៣ ចុងចម្លើយឈ្មោះ **ច១** និងប្រពន្ធឈ្មោះ **ច២** បានខ្ចីចងការប្រាក់នាងខ្ញុំ ប្រាក់ដើមចំនួន ៥០០០ ដុល្លា ដោយគិតការប្រាក់ក្នុងមួយខែចំនួន ២៥០ ដុល្លា។ ចុងចម្លើយបានបង់ការប្រាក់រហូតដល់ឆ្នាំ២០១៥ បានជិតមួយឆ្នាំក៏ឈប់បង់ការប្រាក់រហូតមក។ ហើយក៏មាន ការប្តឹងគ្នាទៅសាលាឃុំ ពេលនោះនាងខ្ញុំទាមទារប្រាក់សរុបទាំងដើម និងការប្រាក់ចំនួន ៨០០០ ដុល្លា ដោយឈប់គិតការប្រាក់ ប៉ុន្តែចុងចម្លើយបានសងមកនាងខ្ញុំសរុបចំនួន ៣០០០ ដុល្លា នៅសល់ចំនួន ៥០០០ ដុល្លា ប្រាក់ដើម។

២. សេចក្តីថ្លែងការណ៍របស់ចុងចម្លើយៈ

ចុងចម្លើយបានអះអាងថា៖ នាងខ្ញុំទទួលស្គាល់ថា នាងខ្ញុំ និងប្តី បានខ្ចីចងការប្រាក់ចំនួន ៥០០០ ដុល្លា ពីដើមចោទពិតមែន ដោយគិតការប្រាក់ក្នុងមួយខែចំនួន ២៥០ ដុល្លា។ ការបង់ការប្រាក់ឱ្យដើមចោទបានចំនួន ១០ ខែ ក៏ឈប់បង់ ហើយដើមចោទបានប្តឹងទៅសាលាឃុំ នាងខ្ញុំបានបង់អោយដើមចោទចំនួន ៣០០០ ដុល្លា ទៀត នាងខ្ញុំទទួលស្គាល់ថា នាងខ្ញុំពិតជានៅជំពាក់ប្រាក់ដើមចំពោះដើមចោទពិតមែន។

III. ចំណុចវិវាទគ្មាន

IV. អំពីភស្តុតាង

-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣។ (ថតចម្លង)

**<u>សំអាងហេតុ</u>**

តាមលទ្ធផលនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

- នាពេលសវនាការដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ចុងចម្លើយបានខ្ចីប្រាក់ពីខ្លួនចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ។ សេចក្តីថ្លែងការណ៍របស់ដើមចោទនេះ អាចឱ្យតុលាការជឿជាក់បានដោយហេតុថា ផ្អែកទៅលើចម្លើយរបស់ចុងចម្លើយនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថាខ្លួនពិតជានៅជំពាក់ប្រាក់ដើមចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ ពិតប្រាកដមែន។

- ផ្អែកលើកិច្ចសន្យាខ្ចីប្រាក់ដែលធ្វើឡើងរវាងដើមចោទ និងចុងចម្លើយ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ តុលាការទទួលស្គាល់ថា កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះត្រូវបានបង្កើតឡើងដោយផ្អែកលើឆន្ទៈរបស់ភាគី ហើយចុងចម្លើយក៏បានទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យានេះឡើងប្រាកដមែន។

- តាមរយៈសេចក្តីថ្លែងការណ៍របស់ដើមចោទ សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ បង្ហាញឱ្យឃើញថា ដើមចោទពិតជាមានអត្ថិភាពនៃសិទ្ធិទាមទារពិតប្រាកដមែន។ ដូច្នេះ គប្បីតុលាការសម្រេចបង្គាប់ឱ្យចុងចម្លើយសងប្រាក់ទៅដើមចោទ។

- ដោយឡែកចំពោះសំណងការខូចខាតចំនួន ១០.០០០.០០០ (ដប់លាន) រៀល ដែលដើមចោទបានធ្វើការទាមទារនេះមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី ហើយ ព្រោះការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយបានធ្វើអោយដើមចោទខាតបង់ពេលវេលា និងថ្លៃសោហ៊ុយក្នុងការធ្វើដំណើរឡើងចុះមកតុលាការ ប៉ុន្តែដោយការទាមទារមានលក្ខណៈច្រើនហួសហេតុបើធៀបទៅនឹងចំនួនប្រាក់ដើមដែលចុងចម្លើយបានជំពាក់ ដូច្នេះ គប្បីតុលាការនឹងធ្វើការសម្រេចផ្តល់សំណងសមរម្យទៅតាមការខូចខាតជាក់ស្តែង។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

- ចំពោះការទាមទារសុំអនុវត្តជាបណ្តោះអាសន្នទៅលើចំណុចទី១ និងចំណុចទី២ នៃសេចក្តីសម្រេច តុលាការយល់ឃើញថា ការអនុវត្តជាបណ្តោះអាសន្នទៅលើចំណុចទី១ មានលក្ខណៈត្រឹមត្រូវហើយ ដោយសារការទាមទារនៅក្នុងរឿងក្តីនេះ ជាប្រភេទនៃការទាមទារដែលពាក់ព័ន្ធទៅនឹងសិទ្ធិលើទ្រព្យសម្បត្តិ។ ដោយឡែក ចំពោះការទាមទារសុំអនុវត្តជាបណ្តោះអាសន្នទៅលើចំណុចទី២ គប្បីតុលាការមិនសម្រេចតាមការទាមទារនោះទេ ដោយហេតុថា ទំហំនៃការទាមទារទៅលើសំណងជម្ងឺចិត្តនៅមិនបានកំណត់ច្បាស់លាស់នៅឡើយ។

- តាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ បង់ប្រាក់ចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ ឱ្យដើមចោទឈ្មោះ ដ ។

២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច២ សងសំណងជម្ងឺចិត្តចំនួន ១.០០០.០០០ (មួយលាន) រៀល ឱ្យដើមចោទឈ្មោះ ដ ។ ច្រានចោលការទាមទារលើសពីនេះ។

៣. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានចំពោះចំណុចទី១ នៃសេចក្តីសម្រេចបញ្ចប់តែប៉ុណ្ណោះ។

៤. ប្រាក់ប្រដាប់ក្តីត្រូវជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយ ទុកសិទ្ធិប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា **ម៉ុក សុវណ្ណមុន្នី**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

**ផៃ ឈុនណា.**

បានឃើញ

**ចៅក្រម**

ម៉ុក សុវណ្ណមុន្នី